# សង្ខេបខ្លឹមសារសាលដីកាតុលាការកំពូលលេខ០៥ I (២០២០)

## សាលដីកានេះអាចរកបាននៅ៖ SC.05(17.01.2020) (measboralaws.com)

**ពាក្យគន្លឹះ៖** មូលដ្ឋានដោះលែង បន្ទុកភស្តុតាង ដំណោះស្រាយសម្រាប់ឃុំខ្លួនលើស
បទរំលោភលើទំនុកចិត្ត

## ក. នីតិវិធីនិងខ្លឹមសារសម្រេច

ជនជាប់ចោទ (ភេទស្រី អាយុ ៣៧ឆ្នាំ) ត្រូវបានចោទពីបទរំលោភលើទំនុកចិត្តនិងក្លែងបន្លំ (អំពើប្រព្រឹត្តខែមីនា ឆ្នាំ២០១៩)។ ចៅក្រមស៊ើបសួរសម្រេចមិនព្រមដោះលែង តាមដីកាលេខ៤១៨ ខែកញ្ញា ឆ្នាំ២០១៩។ ជនត្រូវចោទប្ដឹងប្រឆាំងនឹងដីកាទៅសាលាឧទ្ធរណ៍ ដែលបានតម្កល់ដីកាលេខ៤១៨ដដែល។ ជនត្រូវចោទ បានប្ដឹងសាទុក្ខ មកតុលាការកំពូល។

តុលាការកំពូលយល់ឃើញថា សំអាងហេតុរបស់សាលាឧទ្ធរណ៍ (ដូចគ្នានឹងសាលដំបូង) មិនត្រឹមត្រូវទេ ព្រោះគ្មានភស្តុតាងថា ជនត្រូវចោទធ្វើការគាបសង្កត់លើសាក្សី...សាលាឧទ្ធរណ៍មិនបានពិចារណាអំពីស្ថានភាពជាក់ស្ដែង (ភ្ជាប់នឹងភស្តុតាង) ដែលថាជនត្រូវចោទមានមុខរបរច្បាស់លាស់...។បន្ថែមពីលើនេះ ជនត្រូវចោទបានសារភាព...តុលាការជាន់ទាបបានចេញដីការក្សាការពារហាមលក់ទ្រព្យ...ដើមបណ្ដឹងបានប្ដឹងរដ្ឋប្បវេណី និងកំពុងស្ថិតក្នុងដំណាក់កាលនីតិវិធីអនុវត្តដោយបង្ខំ..។

៣. *យល់ឃើញថា ផ្អែកតាមសំអាងហេតុខាងលើ....ការឃុំខ្លួនបណ្ដោះអាសន្នទៅលើជនត្រូវចោទពុំមានភាពចាំបាច់ស្របតាមបទប្បញ្ញត្តិមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ...តាម..មាត្រា២០៣នៃក្រម(ដដែល) ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព...*។

*៤-យល់ឃើញថា ...ជនត្រូវចោទបានជាប់ឃុំខ្លួនអស់រយៈពេល៥ខែនិង២៤ថ្ងៃហើយ...ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម...មិនអាចលើសពី៤(បួន)ខែបានទេ។ ដូច្នេះ...ឃុំលើសកំណត់ច្បាប់រហូតដល់រយៈពេល១ខែនិង២៤ថ្ងៃហើយ ដែលជាមូលហេតុចាំបាច់ ត្រូវតែសម្រេចដោះលែងឲ្យមានសេរីភាព*។

សម្រេច៖**......២**-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៧៣ (២០១៩ ខែតុលា)...**៣**-ដោះលែងជនត្រូវចោទ...ឲ្យនៅក្រៅការឃុំខ្លួន...។

## ខ. កំណត់សំគាល់

**១.** តុលាការកំពូលពិនិត្យមើលតែការអនុវត្តច្បាប់។ ក្នុងសំណុំរឿងនេះ គឺមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងអំពីមូលដ្ឋាននៃការឃុំខ្លួន។ តុលាការកំពូលបានពិចារណាលើកត្តាពាក់ព័ន្ធបន្ថែមលើស្ថានភាពផ្សេងទៀតដូចជា ស្ថានភាពគ្រួសារ..។

**២.** តុលាការបានផ្តោតជាចម្បងផងដែរលើគោលការណ៍នៃសេរីភាព (presumption of liberty) និងសម្រេចថាការឃុំខ្លួនមិនមានភាពចាំបាច់។ សូមអានបន្ថែមអត្ថបទ៖ 272b8b3f3ae40eee7a7bb87af3971985.pdf។ ជាមួយគ្នានេះដែរ ផ្អែកលើមូលដ្ឋាននេះ និងការណ៍ដែល ការឃុំខ្លួនលើសកំណត់ច្បាប់ តុលាការបានសម្រេចដោះលែងជនត្រូវចោទ។

**៣.** តុលាការបាន អះអាងថា ពុំមានភស្តុតាងបញ្ជាក់អំពីការគាបសង្កត់សាក្សី ទោះបីជាយ៉ាងនេះក្តីយើងមិនអាចដឹងថា តើភាគីណាជាអ្នកបង្ហាញភស្តុតាង។ ជាទ្រឹស្តី និងការអនុវត្តរបស់តុលាការ (អវតក) ជនត្រូវចោទមានបន្ទុកបង្ហាញភស្តុតាងថា មូលដ្ឋាននៃការឃុំខ្លួនលែងមានហើយ ដែលត្រូវដោះលែងខ្លួន។

**៤.** តាមខ្លឹមសារសាលដីកានេះ តុលាការជាន់ទាប ត្រូវពិចារណាភស្តុតាងឲ្យបានគ្រប់ជ្រុងជ្រោយ..។

ខ្លឹមសារពាក់ព័ន្ធមូលដ្ឋានឃុំខ្លួនសូមមើលសាលដីកាតុលាការកំពូលលេខ៣៨៥VIII (សីហាឆ្នាំ២០២២)៖ 3b59921825b19bc026d6efabf6b5ee8b.pdf (measboralaws.com) ការឃុំខ្លួនខុសច្បាប់ជាមូលដ្ឋាននៃការសម្រាលទោស៖ c805bd96d01116b7f9fbc3e2c690179b.pdf(measboralaws.com) តុលាការប្រទេសប្រ៊ុយណេ សម្រេចផ្តល់សំណងចំពោះការឃុំខ្លួនខុសច្បាប់៖ Measboralaws